ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សេចក្តីជូនដំណឹង

ក្នុងការរួមចំណែកអនុវត្តយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានកិត្តិយសសូមជម្រាបជូនសាធារណជនឲ្យបានជ្រាបថា ៖

- មកដល់ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០១៤ នេះ លទ្ធផលសម្រេចបានលើការអនុវត្តបទបញ្ជាលេខ ០១ បប **នយោបាយចាស់សកម្មភាពលើវិស័យដីធ្លី**ក្នុងការវាស់វែងដីធ្លី និងចេញប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ រួមមាន ៖ ប្រកាសតំបន់វិនិច្ឆ័យចំនួន **៣៥៧ ឃុំ** បំពេញសលាកបត្របាន**ជាង ៧១ ម៉ឺនក្បាលដី** វាស់វែងបាន **៧១ ម៉ឺនក្បាលដី** បិទផ្សាយបាន **៧១ ម៉ឺនក្បាលដី** និងចែកប័ណ្ណដល់ដៃប្រជាពលរដ្ឋបាន **៥៦ ម៉ឺនប័ណ្ណ** ។
- មកដល់ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០១៤ ពាក់ព័ន្ធនឹងឯកសារគតិយុត្តបម្រើឲ្យបទបញ្ជាលេខ ០១ បប រាជរដ្ឋាភិបាលបានធ្វើអនុបយោគកាត់ផ្ទៃដីសរុបទំហំ**ជាង ១ លាន ហិកតា** ដែលក្នុងនោះ ទំហំ **ជាង ៣៧ ម៉ឺនហិកតា** កាត់ចេញពីក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចចំនួន **១៣៤** និងទំហំ**ជាង ២៥ ម៉ឺនហិកតា** កាត់ចេញពីក្រុមហ៊ុនព្រៃសម្បទានចំនួន **១៧** និងទំហំ**ជាង ៥២ ម៉ឺនហិកតា** កាត់ចេញពីដីរដ្ឋនិងដីព្រៃមានដីកាដកហូត ដើម្បីផ្តល់កម្មសិទ្ធិជូនប្រជាពលរដ្ឋ តាមរយៈព្រះរាជក្រឹត្យចំនួន **១០២** អនុក្រឹត្យចំនួន **៧១៤** និងសេចក្តីសម្រេចផ្តល់គោលការណ៍របស់រាជរដ្ឋាភិបាលចំនួន **៧៧៧ ស.ជ.ណ**។
- មកដល់ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០១៤ នេះ លទ្ធផលសម្រេចបានលើការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធ តាមរយៈកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី (LASSP)ទាំង **២៥** រាជធានី-ខេត្ត បាននិងកំពុងអនុវត្តនៅស្រុកចំនួន **៩៦ ស្រុក** ឃុំចំនួន **៤៣៥ ឃុំ** និងភូមិចំនួន **៣.៨០៤ ភូមិ** រួមមាន ៖ បញ្ចូលទិន្នន័យបាន**ជាង ៣ លានក្បាលដី** បិទផ្សាយចប់បាន**ជាង ២,៨ លានក្បាលដី** និងចែកប័ណ្ណដល់ដៃប្រជាពលរដ្ឋបាន**ជាង ២,៥ លានប័ណ្ណ** ។
- មកដល់ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០១៤ នេះ លទ្ធផលសម្រេចបានលើការចុះបញ្ជីដីធ្លីលក្ខណៈដាច់ដោយដុំបានចំនួន**ជាង ៦០ ម៉ឺនប័ណ្ណ**។

**លទ្ធផលសរុបនៃការចេញប័ណ្ណកម្មសិទ្ធិជូនដល់ដៃប្រជាពលរដ្ឋបានចំនួនជាង ៣,៦ លានប័ណ្ណ។**

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៤

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

*អាសយដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុន្នីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ*

Tel / Fax : 023 215 279 / (855-23) 215 660, e-mail : mlmupc@mlmupc.gov.kh